ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

វិច្ឆិកា ២០០៧ / November 2007

ផាន់ ដាលីស / Phann Dalis

ប៉ុន ដូរីណា / Pon Dorina

ហ៊ីង វុត្ថា / Hing Vutha

ភីម រុនស៊ីណារិទ្ធិ / Phim Runsinarith

បកប្រែដោយ: យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី២ ឆ្នាំ២០០៧ វិនិយោគឯកជន និងសារធារណៈ មានតំលៃ ២៩១,៤ លានដុល្លារ រឺធ្លាក់ចុះ ៨៨% ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៦។ វិនិយោគសារធារណៈមានតំលៃ ១០០,១លានដុល្លារ រឺកើន ៤,២% រីឯ វិនិយោគឯកជន ធ្លាក់ចុះ ៩២% មកត្រឹម ១៩១,៣ លានដុល្លារ ។

In the second quarter of 2007 public and private investments were USD 291.4 m, a decrease of 88 percent from the same quarter in 2006. Public investment was USD 100.1 m, an increase of 4.2 percent, while private investments declined by 92 percent to USD 191.3 m.

**Public and Private Investment**
2005 Q1–2007 Q2




*Including expansion projects.*
Source: MEF and Council for the Development of Cambodia

នៅខែសីហា ២០០៧ មានភ្ញៀវមកដល់កម្ពុជា ១៤៦.៥៦៥នាក់ រឺកើន ២,៣% ធៀបខែមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស មាន ៦៥% នៃភ្ញៀវចូលសរុប ក្នុងនេះ ២៧% មកតាមអាកាសយានដ្ឋានភ្នំពេញ និង ៣៨% មកតាមអាសកាសយានដ្ឋានសៀមរាប ។ ភ្ញៀវចូលតាមផ្លូវគោក មាន ៣៣% និងផ្លូវទឹក មាន ២,០% ។ ភ្ញៀវមកសំរាកលំហែ កើន ៧,៧% ធៀបនឹងខែមុន ដល់ ១២៨.៩០៥នាក់ ។

In August 2007, there were 146,565 arrivals in Cambodia, an increase of 2.3 percent from the previous month. Arrivals by air made up 65 percent of that total, of which 27 percent was received by Phnom Penh airport, and another 38 percent by Siem Reap airport. Arrivals by land were 33 percent and by water, 2.0 percent. Holiday visitors increased by 7.7 percent from the preceding month to 128,905.

**Cambodia: Foreign Visitor Arrivals**
May 2006–August 2007




Source: Ministry of Tourism

នៅត្រីមាសទី២ ឆ្នាំ២០០៧ គំរោងសាងសង់បានទទួលការអនុមតិនៅក្រុងភ្នំពេញមានសរុប ២១៣,០លានដុល្លារ រឺកើនលើសមួយជាពីរ ធៀបនឹងត្រីមាសមុន ។ ការអនុមតិសំរាប់សំណង់ភូមិគ្រឹះនិងផ្ទះធម្មតា កើនប្រហែលមួយជាបួន ដល់ ៤១,៤លានដុល្លារ និងសំរាប់សំណង់ផ្ទះល្វែងកើនជិតមួយជាពីរ ដល់ ៧២,២លានដុល្លារ ។

In the second quarter 2007, Phnom Penh construction approvals totalled USD 213.0 m, an increase of more than twofold the value of the previous quarter. Villa and house approvals rose approximately fourfold to USD 41.4m, and flat approvals nearly doubled to USD 72.2 m.

**Phnom Penh: Value of Construction Approvals**
2005 Q2–2007 Q2




Source: Phnom Penh Municipality

# ថ្លៃទំនិញ និង អត្រាការប្រាក់លើប្រាក់បញ្ញើ
# Consumer Prices and Interest Rates on Deposits

នៅខែកញ្ញា ២០០៧ ថ្លៃទំនិញទូទៅ កើន ១,៧% ធៀបនឹងខែមុន ក្នុងនេះ ថ្លៃគ្រឿងបរិភោគ ភេសជ្ជៈ និង ថ្នាំជក់ កើន ៣,៦% រីឯ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ ថយចុះ ០,១% ។ ធៀបនឹងខែដូចគ្នានៅឆ្នាំ២០០៦ ថ្លៃទំនិញទូទៅកើន ៦,៤% ក្នុងនេះ ថ្លៃគ្រឿងបរិភោគ ភេសជ្ជៈ និងថ្នាំជក់ កើន ១៣% ហើយថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ កើន ២,០% ។

In September 2007, overall prices increased by 1.7 percent from the previous month. Behind the change in all item prices, food, beverage and tobacco prices rose by 3.6 percent, while transportation and communication costs declined by 0.1 percent. Compared to the same month in 2006, overall prices increased by 6.4 percent, of which food, beverage and tobacco prices rose by 13 percent, and transportation and communication increased by 2.0 percent.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

July 2006–September 2007




Source: National Institute of Statistics

ថ្លៃសាំងបន្តកើនឡើង បន្ទាប់ពីការធ្លាក់ចុះ នៅខែមីនា ២០០៧។ នៅខែតុលា ២០០៧ សាំងលក់ថ្លៃ ៤២២០រៀល/លីត្រ រឺកើន ៤,២% ធៀបនឹងខែមុន ។ ម៉ាស៊ូតឡើងថ្លៃ ៦,៧% ដល់ ៣៤៧២រៀល/លីត្រ ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ សាំង និង ម៉ាស៊ូត ឡើងថ្លៃ ២,៧% និង ៤,៤% ។

Gasoline price continued to increase since the decrease of March 2007. In October 2007, gasoline traded at 4220 riels/ℓ, a rise of 4.2 percent from the month before. The price of diesel rose by 6.7 percent, selling at 3472 riels/ℓ. Compared to the same month in 2006, both gasoline and diesel prices increased, by 2.7 percent and 4.4 percent, respectively.

**Phnom Penh: Gasoline & Diesel Prices**

August 2006–October 2007




Sources: CDRI and National Institute of Statistics

នៅខែកក្កដា ២០០៧ អាត្រាការប្រាក់ផ្តល់ដោយធនាគារធំៗបីដល់អ្នកផ្ញើប្រាក់ នៅតែមានស្ថិរភាព ដូចនៅឆ្នាំ២០០៥ ដែរ ។ សំរាប់បញ្ញើប្រាក់រៀលរយៈ១២ខែ ធនាគារកាណាឌីយ៉ា ផ្តល់ ៦,០% ធនាគារអេស៊ីលីដា ៨,០% និងធនាគារពាណិជ្ជកម្មក្រៅប្រទេស (FTB) ៦,៥% ។ សំរាប់បញ្ញើជាដុល្លារ ធនាគារកាណាឌីយ៉ា និង អេស៊ីលីដា ផ្តល់អាត្រាស្មើគ្នា គឺ ៦,០% រីឯ ធនាគារពាណិជ្ជកម្មក្រៅប្រទេស ផ្តល់ ៥% ។

In July 2007, the interest rates provided by the three major banks to depositors remained stable, as in 2005. Riel 12-month bank deposit offered by Canadia Bank was 6.0 percent, ACLEDA Bank, 8.0 percent and the Foreign Trade Bank (FTB), 6.5 percent. For US dollar deposits, both Canadia and ACLEDA Banks offered the same rate of 6.0 percent, while the rate quoted by FTB was 5.0 percent.

**Interest Rates on 12-Month Bank Deposit**

(As of July 2007)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

ប្រាក់រៀលប្តូរបាន ៤០៦៨,១រៀល/ដុល្លារUS នៅខែតុលា ២០០៧ រឹងឡើងថ្លៃ ០,៣% ធៀបនឹងខែមុន ។ ទល់នឹងដុល្លារ តំលៃប្រាក់រៀលកើនឡើងចាប់ពីខែកក្កដា ២០០៧ ។ ធៀបនឹងខែដូចគ្នា នៅឆ្នាំ២០០៦ ប្រាក់រៀលឡើងថ្លៃ ២,៩% ទល់នឹងដុល្លារ ។

Riel traded at 4068.1 riels/USD against the US dollar in October 2007, an appreciation of 0.3 percent from the preceding month. In relation to the US dollar, the value of the riel improved from July 2007. Compared to the same month in 2006, the riel appreciated by 2.9 percent against the US dollar.

**Riels per US Dollar**

August 2006–October 2007




Sources: National Bank of Cambodia and CDRI

នៅខែតុលា ២០០៧ ប្រាក់រៀលចុះថ្លៃ ១,៣% ទល់នឹងប្រាក់បាតថៃ ធៀបនឹងខែមុន ដោយប្តូរបាន ១២៨,៨រៀល/បាត ។ ផ្ទុយទៅវិញតំលៃប្រាក់រៀលធ្លាក់ចុះ ០,៥% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្តូរបាន ២៥,៤រៀល/១០០ដុង ។

In October 2007, the riel depreciated by 1.3 percent against the Thai baht, compared to the preceding month when it traded at 128.8 riels/baht. By contrast, the value of the riel was down by 0.5 percent against the Vietnamese dong; trading at 25.4 riels per 100 dong.

**Riels per THB & VND**

August 2006–October 2007




Source: CDRI

នៅឆ្នាំ២០០៦ វិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដី ទទួលបាន ៤៥,៥លានដុល្លារ ។ វិស័យនេះរួមមាន រដ្ឋបាលនិងគោលនយោបាយវិស័យជនបទ អនុវិស័យរដ្ឋបាលព្រៃឈើ ការរៀបចំ/ធ្វើផែនការដីធ្លី អនុវិស័យបោសសំអាតមីន ។ល។ ក្នុងរវាងឆ្នាំ២០០០-២០០៦ វិស័យអភិវឌ្ឍន៍ជនបទ និងរៀបចំដែនដី ទទួលបានជំនួយអភិវឌ្ឍន៍ ៣៧១,១ លានដុល្លារ ។

In 2006, the rural development and land management sector was allocated USD 45.5 m. The sector, includes the rural sector policy and administration sub-sector, forestry, land management and spatial planning, the land mine clearance sub-sector, and so on. During the period 2000–2006, the sector was provided with USD 371.1 m in development assistance.

**External Development Assistance Disbursement: Rural Development and Land Management Sector**

2000–2006




Source: CDC, Cambodia Aid Effectiveness Report 2007

# ការអភិវឌ្ឍន៍រូបិយវត្ថុ
# Monetary Developments

នៅខែសីហា ២០០៧ រូបិយវត្ថុទូទៅ (M2) មានអាត្រាកំណើនប្រចាំឆ្នាំ ១២៣% រីឯការផ្គត់ផ្គង់រូបិយវត្ថុ (M1) ថយចុះតាមអាត្រាប្រចាំឆ្នាំ ៩,២% ។ ក្នុងរយៈ១២ខែដល់ខែសីហា រូបិយវត្ថុទូទៅ (M2) កើន ៥៤% ធៀបនឹង អត្រាកំណើន ៤៧% ក្នុងរយៈ១ឆ្នាំ ដល់ខែកក្កដា ២០០៧ ។

The annual growth rate of liquidity (M2) was 123 percent, and money supply (M1) declined at an annualised rate of 9.2 percent in August 2007. Over the previous 12 months, M2 grew at 54 percent, compared to a growth rate of 47 percent in the year to July 2007.

**Monetary Survey**
June 2006–August 2007




Source: National Bank of Cambodia

នៅខែសីហា ២០០៧ ឥណទានក្នុងស្រុក កើនតាមអាត្រាប្រចាំឆ្នាំ ១៥៥% ហើយឥណទានក្នុងវិស័យឯកជន កើនតាមអាត្រាប្រចាំឆ្នាំ ១០១% ។ ក្នុងរយៈ១២ខែដល់ខែសីហា ឥណទានក្នុងស្រុក កើន ៦២% ធៀបនឹង កំណើន ៥៥% ក្នុងរយៈ១ឆ្នាំដល់ខែកក្កដា ២០០៧ ។

In August 2007, domestic credit grew at an annualised rate of 155 percent and private sector credit grew at an annualised rate of 101 percent. Over the 12 months to August, domestic credit grew by 62 percent, compared to 55 percent in the year to July 2007.

**Domestic Credit**
June 2006–August 2007




Source: National Bank of Cambodia

នៅខែសីហា ២០០៧ ឥណទានក្នុងវិស័យឯកជន កើន ៦,០% ធៀបនឹង ខែមុនដល់ ៥១៨២,៧ពាន់លានរៀល រីឯទ្រព្យសកម្មបរទេសសុទ្ធ កើន ៤,៥% ដល់ ៩៤៩៧,០ពាន់លានរៀល ។ ឥណទានរដ្ឋាភិបាល ធ្លាក់ចុះ ០,៥% មកត្រឹម ២៩៦,៧ពាន់លានរៀល ហើយបញ្ញើរបស់រដ្ឋាភិបាល កើន ០,៧% ដល់ ១៧៥៣,៣ពាន់លានរៀល ។ ក្នុងរយៈពេលដដែល ខ្ទង់ "ផ្សេងៗ" ធ្លាក់ចុះ ១,៨% មកត្រឹម ៣៥០៥,៧ពាន់លានរៀល ។ ប្រតិបត្តិការហិរញ្ញវត្ថុបានបង្កើនរូបិយវត្ថុ ៦,៩% ដល់ ៩៧១៧,៤ ពាន់លានរៀល ។

Private sector credit in August 2007 increased by 6.0 percent from the preceding month to KHR 5182.7 bn, and net foreign assets (NFA) rose by 4.5 percent to KHR 9497.0 bn. Government credit decreased by 0.5 percent to KHR 296.7 bn and government deposits rose by 0.7 percent to KHR1753.3 bn. At the same time, a negative sign was "other items" falling by 1.8 percent to KHR 3505.7 bn. The monetary operation increased liquidity by 6.9 percent to KHR 9717.4 bn.

**Monetary Assets**
June 2006–August 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅខែកក្កដា ២០០៧ ការនាំចេញរបស់កម្ពុជា មាន ២៨៦,៩លានដុល្លារ រឺធ្លាក់ចុះ ១០% ធៀបនឹងខែមុន។ ការនាំចេញក្នុងវិស័យកាត់ដេរធ្លាក់ចុះ ១១% មកត្រឹម ២៧៨,៤លានដុល្លារ ។ ការនាំចេញត្រីធ្លាក់ចុះ ៨,៨% មកត្រឹម ០,២លានដុល្លារ រីឯ ការនាំចេញកៅស៊ូកើន ៥,៩% ដល់ ៣,៧លានដុល្លារ ។ ការនាំចេញសរុប កើន ៩,៨% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ។ (ទិន្នន័យការនាំចេញសំរាប់ខែសីហាមិនទាន់មានទេ)

In July 2007, Cambodia's exports amounted to USD 286.9 m, a decrease of 10 percent from the previous month. Garment exports dropped by 11 percent to USD 278.4 m; fish exports fell by 8.8 percent to USD 0.2 m, while rubber exports increased by 5.9 percent to USD 3.7 m. Total exports, however, increased by 9.8 percent from the same month in 2006. (Export data for August is not yet available.)

**Cambodia: Main Exports**
May 2006–July 2007




Source: *Monthly Bulletin of Statistics, MEF website*

ការនាំចូលបារី ធ្លាក់ចុះ ២០% ធៀបនឹងខែមុន មកត្រឹម ៣៧,៦ពាន់លានរៀល រីឯ ការនាំចូលស៊ីម៉ង់តិ៍កើន ២២% ដល់ ១៨,៣ពាន់លានរៀល ហើយការនាំចូលដែកកើន ៦៦% ដល់ ២៥,៨ពាន់លានរៀល ក្នុងខែកក្កដា ២០០៧ ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការនាំចូលបារីធ្លាក់ចុះ ១,៦% រីឯ ការនាំចូលស៊ីម៉ង់តិ៍ និង ដែក កើន ២៩% និង ៥៦% ។ (ទិន្នន័យការនាំចូលសំរាប់ ខែសីហាមិនទាន់មានទេ)

Cigarette imports decreased by 20 percent from the previous month to KHR 37.6 bn, while cement imports increased by 22 percent to KHR 18.3 bn and steel imports rose by 66 percent to KHR 25.8 bn in July 2007. Compared to the same month in 2006, cigarette imports declined by 1.6 percent, while both cement and steel imports rose by 29 percent and 56 percent, respectively. (Import data for August is not yet available.)

**Imports: Cigarettes & Construction Material**
May 2006–July 2007




Source: *Monthly Bulletin of Statistics, MEF website.*Cement revised April, May and June 07.*

នៅខែកក្កដា ២០០៧ ការនាំចូលសាំងមាន ២៣.៥៩២តោន រឺកើន ៣,៨% ធៀបនឹងខែមុន ។ ការនាំចូលម៉ាស៊ូតធ្លាក់ចុះ ០,៧% មកត្រឹម ៤២.៨៥៦ តោន ។ គិតជាតំលៃ ការនាំចូលសាំងកើន ៤,១% ដល់ ២៩,៨ពាន់លានរៀល រីឯ ការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ០,៤% មកត្រឹម ៤៦,៧ពាន់លានរៀល ។ (ទិន្នន័យការនាំចូលសំរាប់ខែសីហា មិនទាន់មានទេ)

In July 2007, gasoline imports were 23,592 tonnes, an increase of 3.8 percent from the previous month. Diesel imports decreased by 0.7 percent to 42,856 tonnes. By value, gasoline imports rose by 4.1 percent to KHR 29.8 bn, while diesel imports dropped by 0.4 percent to KHR 46.7 bn. (The import data for August is not yet available.)

**Imports: Petroleum Products**
May 2006–July 2007




Source: *Monthly Bulletin of Statistics, MEF website*

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែមិថុនា ២០០៧ អតិរេកថវិកាចរន្តកើនមួយជាពីរ ធៀបនឹងខែមុន ដល់ ១០៧,២ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ អតិរេកក៏កើនមួយជាពីរដែរ ។

In June 2007, the current budget surplus was more than twofold the value of the previous month to KHR 107.2 bn. Compared to the same month in 2006, the surplus had doubled in value.

**Current Budget Operations**
January 2006–June 2007




*Note: Provisional for 2007. *Revised May 07*
Source: *Monthly Bulletin of Statistics (MEF website)*

ចំណូលថវិកាចរន្តកើន ១,៩% ធៀបនឹងខែមុន ដល់ ៣៤០,៣ពាន់លានរៀល។ ចំណូលពន្ធក្នុងស្រុកកើន ១,៣% ដល់ ២១២,៥ពាន់លានរៀល ហើយពន្ធការនាំចេញនាំចូល កើន ៦,៩% ដល់ ៩០,១ពាន់លានរៀល រីឯ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៥,៥% មកត្រឹម ៣៧,៧ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ចំណូលថវិការចរន្តមានកំណើនខ្ពស់បង្គួរ ដល់ ១៨%។

Current revenue increased by 1.9 percent from the preceding month to KHR 340.3 bn. Domestic tax collection rose by 1.3 percent to KHR 212.5 bn; import and export taxes increased by 6.9 percent to KHR 90.1 bn, while revenue from non-tax collection declined by 5.5 percent to KHR 37.7 bn. Compared to the same month in 2006, current budget revenue achieved a moderate rise of 18 percent.

**Current Budget Revenue**
January 2006–June 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics (MEF website )*

នៅខែមិថុនា ២០០៧ ចំណាយថវិកាចរន្តថយចុះ ១៩% ធៀបនឹងខែមុន មកត្រឹម ២៣៣,០ពាន់លានរៀល ។ ចំណាយលើបៀវត្សរ៍ ថយចុះ ១៩% ដល់ ៧៨,៤ពាន់លានរៀល ។ ឧបត្ថម្ភធន និង ជំនួយសង្គមកិច្ច មាន ៦៤,៧ពាន់លានរៀល រឺថយចុះ ៣២% ធៀបនឹងខែមុន ។ ធៀបនឹង ខែដូចគ្នា ឆ្នាំ២០០៦ ចំណាយថវិកាចរន្តកើន ១០% ។

Current budget expenditure decreased by 19 percent from the preceding month, to KHR 233.0 bn in June 2007. Spending on wages dropped by 19 percent to KHR 78.4 bn. Subsidies and social assistance expenditure was 32 percent less than the amount spent in the preceding month, recorded as KHR 64.7 bn. Compared to the same month in 2006, however, current expenditure rose by 10 percent.

**Current Budget Expenditure Components**
January 2006–June 2007




*Note: Provisional for 2007.*
Source: *Monthly Bulletin of Statistics (MEF website )*

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែកញ្ញា ការនាំចេញទំនិញរបស់ US កើនឡើង រីឯការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និងជប៉ុន ថយចុះ ។ ការនាំចេញទំនិញរបស់ US កើន ១,៣% ធៀបនឹងខែមុន ដល់ ១០០,២២ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់ តំបន់អឺរ៉ូ និងជប៉ុន ថយចុះ ០,១% និង ១,៧% ធៀបនឹងខែមុន មកត្រឹម ១៧៨,៣៣ពាន់លានដុល្លារ និង ៦១,២២ពាន់លានដុល្លារ ។

In September, goods exports from the US increased, while exports of the Euro zone and Japan decreased. US goods exports rose by 1.3 percent from the previous month to USD100.22 bn. Goods exports of the Euro zone and Japan declined marginally by 0.1 percent and 1.7 percent from the previous month, to USD178.33 bn and USD61.22 bn. respectively.

**Goods Exports: US, Euro zone & Japan**

September 2006–September 2007




Sources: BEA, Eurostat and OECD

នៅខែកញ្ញា ចិនមានអតិរេកពាណិជ្ជកម្ម ២៣,៨០ពាន់លានដុល្លារ ធៀបនឹងអតិរេក ២៤,៩៨ពាន់លានដុល្លារ នៅខែសីហា ។ ការនាំចេញសរុប កើន ០,៩% ធៀបនឹងខែមុន ដល់ ១១២,៣៧ពាន់លានដុល្លារ រីឯការនាំចូលសរុប កើន ២,៥% ដល់ ៨៨,៥៧ពាន់លានដុល្លារ ។

In September, China recorded a trade surplus of USD23.80 bn, compared to USD24.98 bn in August. Total exports rose by 0.9 percent from the previous month to USD112.37 bn, while total imports increased by 2.5 percent to USD88.57 bn.

**External Trade: China**

September 2006–September 2007




Sources: National Bureau of Statistics of China

នៅខែកញ្ញា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ៣,២៧ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,៥៧ពាន់លានដុល្លារ នៅខែសីហា ។ ការនាំចេញ កើន ១,០% ធៀបនឹងខែមុន ដល់ ១៥,៣២ពាន់លានដុល្លារ រីឯការនាំចូលថយចុះ ៥,៤% មកត្រឹម ១២,០៦ពាន់លានដុល្លារ ។

In September, Malaysia recorded a trade surplus of USD3.27 bn, compared to USD2.57 bn in August. Exports rose by 1.0 percent from the previous month to USD15.32 bn, while imports decreased by 5.4 percent to USD12.06 bn.

**External Trade: Malaysia**

September 2006–September 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ថ្លៃទំនិញប្រើប្រាស់នៅ US កើន ២,៨% ក្នុងរយៈមួយឆ្នាំដល់ខែកញ្ញា ។ យោងតាមក្រសួងការងាររបស់ US កំណើននេះបណ្តាលជាសំខាន់មកពីការកើនឡើងថ្លៃម្ហូបអាហារ និងថាមពល ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាមានកំរិត ២,១% នៅតំបន់អឺរ៉ូ និង -0,២% នៅជប៉ុន ។

US consumer prices increased by 2.8 percent in the year to September. According to the U.S Department of Labor, this increase largely reflected higher charges for food and energy. During the same period, the inflation rate was 2.1 percent in the Euro zone and -0.2 percent in Japan.

**Inflation Rate: US, Euro zone & Japan**
(change from a year ago)




*Note: The latest data available are for Sep. 2007*
Sources: IMF and *Economist* (Nov. 15th 2007)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅហុងកុងកើន ១,៦% ក្នុងរយៈមួយឆ្នាំដល់ខែកញ្ញា ២00៧ ។ ការឡើងថ្លៃម្ហូបអាហារ គឺជាកត្តាចំបងដែលធ្វើអោយមានការឡើងថ្លៃទំនិញប្រើប្រាស់សរុប ។ ក្នុងអំឡុងពេលដូចគ្នា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅចិន និងកូរ៉េខាងត្បូង កើន ៦,២% និង ២,៣% ។

Hong Kong's consumer price index rose by 1.6 percent in the year to September 2007. The rise in food prices was the major factor behind the overall price level increase. During the same period, the consumer price indexes in China and South Korea increased by 6.2 percent and 2.3 percent, respectively.

**Inflation Rate: China, Hong Kong & South Korea**
(change from a year ago)




*Note: The latest data available are for Sep. 2007*
Sources: IMF and *Economist* (Nov. 15th 2007)

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន ២,៧% ក្នុងរយៈមួយឆ្នាំដល់ខែកញ្ញា ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ការដឹកជញ្ជូននិងទូរគមនាគមន៍ ការថែទាំសុខភាព និងការសំរាកលំហែ ។ ក្នុងអំឡុងពេលដូចគ្នា អត្រាអតិផរណាក្នុងរយៈមួយឆ្នាំមានកំរិត ១,៨% នៅម៉ាឡេស៊ី និង ២,១% នៅ ថៃ ។

Singapore's consumer price index rose by 2.7 percent in the year to September. The Department of Statistics of Singapore attributed this to higher costs for food, transport and communication, healthcare, and recreation. During the same period, the year-on-year inflation rate was 1.8 percent in Malaysia and 2.1 percent in Thailand.

**Inflation Rate: Selected ASEAN Countries**
(change from a year ago)




*Note: The latest data available are for Sept. 2007*
Sources: IMF and *Economist* (Nov. 15th 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែវិច្ឆិកា ២០០៧ ប្រាក់ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុធំបងៗ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៦៨ អឺរ៉ូ/ដុល្លារUS រឺធ្លាក់ថ្លៃ ៤,១% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១១,១ យ៉េន/ដុល្លារUS រឺធ្លាក់ថ្លៃ ៣,១% ធៀបនឹងខែតុលា ២០០៧ ។ ដុល្លារUS ធ្លាក់ចុះទល់នឹងអឺរ៉ូ និងយ៉េន ដោយសារការវាយស្មានថា ការបាត់បង់ទីផ្សារឥណទានរបស់US នឹងធ្វើអោយធនាគារកណ្តាលUS បន្តបន្ទាបអត្រាការប្រាក់។

In November 2007, the US dollar weakened against major currencies. Against the euro, it traded at 0.68 EUR/USD, a 4.1 percent loss from the previous month. Against the Japanese yen, it exchanged at 111.1 JPY/USD, a 3.1 percent depreciation from October 2007. The dollar declined against the euro and the yen following speculation that U.S. credit-market losses would prompt the Federal Reserve to continue lowering interest rates.

**EUR & JPY Per USD**
Nov 06–Nov 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែវិច្ឆិកា ២០០៧ ប្រាក់វ៉ុនកូរ៉េខាងត្បូងប្តូរបាន ៩១៨,៤៣ វ៉ុន/ដុល្លារUS រឺធ្លាក់ថ្លៃ ០,៤% ធៀបនឹងខែតុលា ២០០៧ ។ ប្រាក់វ៉ុនកូរ៉េខាងត្បូងធ្លាក់ថ្លៃ ដោយសារអ្នកវិនិយោគទុនបរទេសបានកាត់បន្ថយការកាន់កាប់សន្លឹកហ៊ុនរបស់កូរ៉េ ពីព្រោះមានការបារម្ភថា ការខាតបង់របស់ទីផ្សារឥណទាន នឹងពន្យឺតកំណើនសេដ្ឋកិច្ចសកលលោក ។ ក្នុងអំឡុងពេលដូចគ្នាដុល្លារហុងកុងក៏ធ្លាក់ថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៧,៧៨ដុល្លារហុងកុង/ដុល្លារUS ធៀបនឹង ៧,៧៥ដុល្លារហុងកុង/ដុល្លារUS កាលពីខែមុន ។

In November 2007, the South Korean won exchanged at 918.43 KRW/USD against the US dollar, depreciationg by 0.4 percent from October 2007. South Korea's won weakened as overseas investors cut holdings of the nation's stocks on concern that credit-market losses would slow global economic growth. During the same period, the Hong Kong dollar also fell against its US counterpart, trading at 7.78 HKD/USD from 7.75 HKD/USD a month earlier.

**KRW & HKD Per USD**
Nov 06–Nov 07 (Monthly average)




Source: Federal Reserve Bank of New York

នៅខែវិច្ឆិកា ២០០៧ ដុល្លារសិង្ហបុរីឡើងថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ១,៤៤៦ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៤៦៥ដុល្លារសិង្ហបុរី/ដុល្លារUS នៅខែមុន រីឯប្រាក់បាតថៃក៏ឡើងថ្លៃដល់ ៣១,៣៥បាត/ដុល្លារUS ។ រូបិយវត្ថុអាស៊ីឡើងថ្លៃ ដោយសារការវាយស្មានថា ធនាគារកណ្តាលUS នឹងបន្តបញ្ចុះអត្រាការប្រាក់ ដើម្បីស្តារកំណើនសេដ្ឋកិច្ចដ៏យឺតនេះ ។

In November 2007, the Singapore dollar advanced against the US dollar, trading at 1.446 SGD/USD compared to 1.465 SGD/USD a month earlier. The Thai baht also appreciated against the US dollar, exchanging at 31.35 THB/USD. Most Asian currencies gained as the dollar extended declines on speculation that the U.S. Federal Reserve would continue to cut interest rates to revive slowing economic growth.

**THB & SGD Per USD**
Nov 06–Nov 07 (Monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែតុលា ថ្លៃអង្ករពិភពលោក កើនឡើងដោយសារកង្វះខាតការផ្គត់ផ្គង់ និងតំរូវការនាំចូលខ្ពស់ ។ សន្ទស្សន៍ថ្លៃទំនិញអន្តរជាតិ (IPO) មាន ១៤៨,២ពិន្ទុ ធៀបនឹង ១៤៤,២ពិន្ទុ នៅខែកញ្ញា ។ នៅថៃ ថ្លៃអង្ករ Thai 100%B កើន ២,១% ធៀបនឹងខែមុន ដល់ ៣០៧,៤៧ដុល្លារ/តោន ។ នៅសហរដ្ឋអាមេរិក ថ្លៃអង្ករនាំចេញកើន ៦,៩% ធៀបនឹងខែមុន ដល់ ៤១៩,៩៤ ដុល្លារ/តោន។

In October, world rice prices increased due to scarcity of supply and a strong import demand. The International Prices Index (IPO) was 148.2, compared to 144.2 in September. In Thailand, the price of Thai 100%B rose by 2.1 percent from the previous month to USD307.47 per tonne. In the United States, the export price rose by 6.9 percent from the previous month to USD419.94 per tonne.

**Rice: International Prices Index & Export Prices**
October 2006–October 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែវិច្ឆិកា ថ្លៃសណ្តែកសៀង និងពោត កើនឡើង។ សណ្តែកសៀងលក់ថ្លៃ ៣៦៣,៦៥ដុល្លារ/តោន ធៀបនឹង ៣៣៤,៥៦ដុល្លារ/តោន នៅខែតុលា។ ពោតលក់ថ្លៃ ១៥៥,៧៨ដុល្លារ/តោន រីឡើងថ្លៃ ៤,៤% ធៀបនឹងខែមុន។ នៅខែតុលា ប្រេងឆាឡើងថ្លៃ ៥,៥% ធៀបនឹងខែមុន ដល់ ៧៩៩,០៧ដុល្លារ/តោន។

In November, the prices of soybeans and maize increased. Soybeans sold at USD363.65 per tonne, up from USD334.56 per tonne in October. Maize was USD155.78 per tonne, a 4.4 percent increase from the previous month. In October, the price of palm oil increased by 5.5 percent from the previous month to USD799.07 per tonne.

**Prices: Soybeans, Maize & Palm Oil**
November 2006–November 2007




Source: Food and Agriculture Organisation (FAO)

នៅខែវិច្ឆិកា ប្រេងឆៅ សាំង និងម៉ាស៊ូត ឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៨៨,៥៧ដុល្លារ/ធុង ធៀបនឹង ៧៨,៦៥ដុល្លារ/ធុង នៅខែតុលា។ នៅ US Gulf Coast ថ្លៃសាំងធម្មតា (អុកតាន ៨៧) ឡើង ១២% ធៀបនឹងខែមុន ដល់ ៦២,៧១សេន/លីត្រ។ ថ្លៃម៉ាសូត (មានលាយស្ពាន់ធ័រតិច លេខ២) កើនឡើង ១៣,៦% ធៀបនឹងខែមុន ដល់ ៦៩,៤៨សេន/លីត្រ។

In November, the prices of crude oil, gasoline and diesel increased. The OPEC spot price of crude oil was USD88.57 per barrel, against USD78.65 in October. Regular gasoline (87 octane) prices on the US Gulf Coast rose by 12 percent from the previous month to 62.71 cents per litre. Diesel (low sulphur No.2) on the US Gulf Coast increased by 13.6 percent from the previous month, to 69.48 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
November 2006–November 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ប្រទេសកម្ពុជា យល់ព្រមលើកិច្ចព្រមព្រៀងដឹកជញ្ជូនទំនិញ និងធ្វើដំណើរឆ្លងព្រំដែន:** រដ្ឋសភាកម្ពុជាបានអនុម័តកិច្ចព្រមព្រៀងដើម្បីសំរួលការដឹកជញ្ជូនទំនិញ និងមនុស្សឆ្លងព្រំដែនជាមួយប្រទេសឯទៀតក្នុងតំបន់។ ឯ.ឧ ជុំ អៀក រដ្ឋលេខាធិការក្រសួងសាធារណៈការនិងដឹកជញ្ជូន បញ្ជាក់ថា កម្ពុជាបានចុះកិច្ចព្រមព្រៀងបែបនេះរួចហើយជាមួយ ចិន វៀតណាម ឡាវ មីយ៉ាន់ម៉ា និង ថៃ។ លោកជំទាវ គី លំអង ប្រធានគណៈកម្មការដឹកជញ្ជូន និងទូរគមនាគមន៍ លើកថា កិច្ចព្រមព្រៀងនឹងជួយទប់ស្កាត់ការរត់ពន្ធគ្រឿងញៀន និងទំនិញផុតកាលកំនត់ ចូលមកប្រទេសកម្ពុជា។ ឯ.ឧ ជាម យៀប ប្រធានគណៈកម្មការធនាគារនិងហិរញ្ញវត្ថុ បញ្ជាក់ថា វាជួយបង្កើនចំណូលពន្ធ និងបញ្ឈប់ការនាំចូលមាន់ជ្រូកខុសច្បាប់ពីប្រទេសជិតខាង។

***Cambodia approves agreements on cross-border transportation of cargo and people:*** The Cambodian National Assembly approved agreements to facilitate cross-border transportation of cargo and people with other countries in the region. Cambodia has already signed such agreements with China, Vietnam, Laos, Myanmar and Thailand, said Chum Iek, secretary of state in the Ministry of Public Works and Transportation. These agreements will help to combat drug trafficking and prevent expired products from flowing into Cambodia, Ky Lum Ang, chairwoman of the Committee of Transportation and Telecommunication, said. In addition, they will help collect tax for national revenue and halt the importation of unauthorised chicken and pork from neighbouring countries, said Cheam Yeap, chairman of the Committee of Banking and Finance. *(Cited from Xinhua 09/11/2007)*

**ក្រុមហ៊ុនបារាំង Alstom មានផែនការធ្វើអាជីវកម្មរថភ្លើងអគ្គិសនីនៅកម្ពុជា:** សហគ្រាសបារាំងមួយបញ្ជាក់ថា ខ្លួនមានគំរោងដំណើរការរថភ្លើងអគ្គិសនី នៅរាជធានីភ្នំពេញ និងក្រុងសៀមរាប ដើម្បីជួយកាត់បន្ថយការស្ទះចរាចរណ៏ និងការបំពុលបរិយាកាស។ លោក Jean Lousiv Menuel ប្រធាន Alstom បានបង្ហាញគំរោងនេះនៅពេលជួបប្រជុំថ្មីៗ រវាងគណៈប្រតិភូពាណិជ្ជករបារាំងមួយ និង ឯ.ឧ កែប ជុតិមា អភិបាលក្រុងភ្នំពេញ។ លោក Menuel បានលើកថា រថភ្លើងអគ្គិសនីនឹងជួយរក្សាបរិស្ថាន និងសោភណភាពទីក្រុង។ តាមគំរោងនេះ ផ្លូវរថភ្លើងមួយនឹងភ្ជាប់តំបន់ជាយក្រុងភ្នំពេញ ចាប់ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មកកណ្តាលក្រុង។ ឯ.ឧ អភិបាលក្រុងបានគាំទ្រទាំងស្រុងដល់គំរោង ដោយបញ្ជាក់នូវសេចក្តីសង្ឃឹមពីការថយចុះការស្ទះចរាចរណ៏ក្នុងទីក្រុងបង្កឡើងដោយកំណើនយ៉ាងខ្លាំងនៃចំនួនយានយន្តតាមដងផ្លូវ និងការត្រៀមសហការរបស់សាលាក្រុងភ្នំពេញ ជាមួយនឹង Alstom ដើម្បីធ្វើការសិក្សាពីភាពអាចធ្វើបាន។

***France's Alstom Plans To Operate Trams In Cambodia.*** A French firm has said it plans to operate trams in Phnom Penh, the Cambodian capital, and Siem Reap to help reduce the number of traffic jams and ease air pollution. Jean Lousiv Menuel, president of Alstom, presented his company's plan to run trams in Phnom Penh and later in Siem Reap province during a recent meeting between a French business delegation and Phnom Penh Municipal Governor Kep Chuktema. The tram railways will maintain the environment and beauty of the cities, Jean Lousiv Menuel was quoted as saying. According to the plan, a railway to be called Tramway will connect the outskirts of Phnom Penh to its city centre, from Phnom Penh International Airport to the centre. Kep Chuktema offered his support for the plan, saying that he hopes it will help reduce traffic jams in the city just as the number of vehicles on the roads is markedly increasing. He said the municipality would cooperate with Alstom to carry out a feasibility study.
*(Cited from au.news.yahoo.com 27/11/2007)*

**ប្រទេសកម្ពុជានឹងបង្កើតក្រុមហ៊ុនអាកាសចរជាតិមួយ ជាមួយក្រុមហ៊ុនឥណ្ឌូនេស៊ី:** រដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀង（MOU）ជាមួយនឹងក្រុមហ៊ុនឥណ្ឌូនេស៊ី គឺ PT Rajawali Group និង PT Ancora International ដើម្បីបង្កើតក្រុមហ៊ុនអាកាសចរជាតិមួយ ។ រដ្ឋាភិបាលកម្ពុជាកាន់កាប់ភាគហ៊ុន ៥១% ប៉ុន្តែទទួលប្រាក់ចំនេញត្រឹម ៣០% ប៉ុណ្ណោះ។ ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុននេះត្រូវតែងតាំងដោយរដ្ឋាភិបាលកម្ពុជា រីឯអគ្គនាយក និងនាយកប្រតិបត្តិ CEO នឹងត្រូវតែងតាំងដោយខាងពួកក្រុមហ៊ុន។ ក្រុមហ៊ុនអាកាសចរណ៏នេះ នឹងផ្តល់ជើងហោះហើរក្នុងស្រុក និងអន្តរជាតិ ហើយជើងហោះហើរអន្តរជាតិដំបូង នឹងផ្តោតសំខាន់លើប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូង ដែលសំបូរអ្នកទេសចរមកទស្សនាប្រទេសកម្ពុជា។

***Cambodia to set up national airline with Indonesian companies:*** The Cambodian government signed a memorandum of understanding (MOU) with Indonesian companies, PT Rajawali Group and PT Ancora International company, to establish a national airline as its national flag carrier. The Cambodian government holds a 51 percent stake and receives only 30 percent of the profit. The chairman of the board for this airline will be appointed by the Cambodian government, but the General Manager and CEO will come from the companies, he added. This airline will provide domestic and international flights and the first international flights will focus on China, Japan and South Korea, from which countries many people visit Cambodia as tourists. *(Cited from Xinhua 23/11/2007)*